bohong

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យា

## ស្តីពី

## ការវិនិយោគទុនលើដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ

រវាង

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

និង

## ក្រុមហ៊ុន លាង ហួហុង អាហារណ៍ និហារណ៍ និងអភិវឌ្ឍន៍ដំណាំ កសិ-ឧស្សាហកម្ម និង កែច្នៃ

កិច្ចសន្យានេះធ្វើឡើងរវាង :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តំណាងដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានអាស័យដ្ឋានលេខ 200 មហាវិថីព្រះនរោត្តម ទូរស័ព្ទលេខ ( 855 ) 23.427.320 មាន គណនីលេខ 01.063.220 នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស ហៅថាភាគី " ក " ។

និង

ក្រុមហ៊ុន លាង ហួហុង អាហារណ៍ និហារណ៍ និង អភិវឌ្ឍន៍ដំណាំ កសិ-ឧស្សាហកម្ម និង កែច្នៃ តំណាងដោយលោក **លី ហាន** ឋានៈជានាយកក្រុមហ៊ុន មានស្នាក់ការនៅផ្ទះលេខ 863 ក្រុម 42 ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ខេត្តបាត់ដំបង ទូរស័ព្ទលេខ ( 855 ) 012 530120 ទូរសារលេខ ( 855 ) 053 952074 មានគណនីលេខ 801-03-201-357-1 នៅធនាគារ កម្ពុជាពាណិជ្ជ ចំពោះហៅថាភាគី " ខ " ។

-យោងតាមលិខិតជូនដំណឹងលេខ 1054 សជណ ចុះថ្ងៃទី 04 ខែសីហា ឆ្នាំ 1999 របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការយល់ព្រមផ្តល់ដីសម្បទានចំនួន 8.000 ហិកតា ជូនទៅក្រុមហ៊ុន លាង ហួហុង អាហារណ៍ និហារណ៍ អភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ និងលិខិតលេខ 244/99 គវក ចុះថ្ងៃទី 19 ខែមិថុនា ឆ្នាំ 1999 របស់គណៈកម្មាធិការវិនិយោគកម្ពុជា ។

-លិខិតប្រទានសិទ្ធិរបស់រាជរដ្ឋាភិបាលលេខ 18 សប្រទ ចុះថ្ងៃទី 05 ខែមេសា ឆ្នាំ 2000

-ដោយផ្អែកលើច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយមានដូចខាងក្រោមនេះ :

## ការ ១ : កម្មវត្ថុនៃកិច្ចសន្យា

កម្មវត្ថុនៃកិច្ចសន្យានេះគឺភាគី " ក " យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួន 8.000 ហិកតា ស្ថិតនៅតំបន់ទ្រនាប់ដែនជំរកសត្វព្រៃនាមឈូនសំ ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង ( ដូចមាន ផែនទីជូនភ្ជាប់ ) ជូនទៅភាគី "ខ" កាន់កាប់ប្រើប្រាស់ធ្វើអាជីវកម្មផលិតកម្មកសិកម្ម ។ ទំហំផ្ទៃដី នេះបានបញ្ជាក់កាន់តែច្បាស់ក្នុងផែនទីចម្លងពីតាំង ដែលភ្ជាប់ជាមួយឧបសម្ព័ន្ធនៃកិច្ចសន្យានេះ ដែល ចាប់ពីពេលនេះតទៅហៅថា " ពីតាំង " ហើយមានអាសយដ្ឋានដូចខាងក្រោម :

| | | | |
|---|---|---|---|
| A = ( $X_1$ = 44° | $Y_1$ = 30° ) ; | B = ( $X_2$ = 50° | $Y_2$ = 30° ) |
| C = ( $X_3$ = 50° | $Y_3$ = 38° ) ; | D = ( $X_4$ = 52° | $Y_4$ = 38° ) |
| I = ( $X_5$ = 52° | $Y_5$ = 40° ) ; | F = ( $X_6$ = 54° | $Y_6$ = 40° ) |
| G = ( $X_7$ = 54° | $Y_7$ = 46° ) ; | H = ( $X_8$ = 56° | $Y_8$ = 46° ) |
| I = ( $X_9$ = 56° | $Y_9$ = 50° ) ; | J = ( $X_{10}$ = 59°45' | $Y_{10}$ = 53° ) |
| K = ( $X_{11}$ = 58° | $Y_{11}$ = 54° ); | L = ( $X_{12}$ = 50°45' | $Y_{12}$ = 48°20' ) |

ពីចំណុច A ភ្ជាប់ចំណុច L ស្ថិតតាមបណ្តោយដងស្ទឹងមង្គលបូរី ) ។

ទំហំដីសរុបចំនួន 8.000 ហិកតា ខាងលើមាន :

1.1 ដីដែលភាគី "ខ" អាចធ្វើអាជីវកម្មដោយផ្ទាល់

1.2 ដីជាកម្មសិទ្ធិរបស់ពលរដ្ឋកាន់កាប់ដោយស្របច្បាប់ ដីមួយចំនួនទៀតជិតៗភូមិ សំរាប់ប្រជាជនធ្វើការ អភិវឌ្ឍន៍ដែលត្រូវកាត់ចេញ ឬក្រុមហ៊ុនអាចសហការធ្វើអាជីវកម្មជាមួយពលរដ្ឋដោយមានការយល់ព្រម ពីរភាគីទាំងសងខាង ។ ករណីមានការរំលោភកាន់កាប់ដីសម្បទាននេះដោយខុសច្បាប់ ភាគី "ខ" មានសិទ្ធិ ប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ច ។

1.3 ដីជាដីភ្នំ-ជីអាងទឹក និងស្ទឹងៗ ដែលត្រូវរក្សាទុកអោយស្ថិតនៅជាលក្ខណៈធម្មជាតិ ។

1.4 ទំហំផ្ទៃដីដែលមានចែងក្នុងចំនុច 1.1, 1.2, 1.3 ភាគី "ក" និងភាគី "ខ" ត្រូវសហការនិងស្ថាប័ន មានសមត្ថកិច្ចសិក្សាស្រាវជ្រាវអង្កេត និងកំនត់ច្បាស់លាស់ក្នុងរយៈពេល 03 ខែ ក្រោយពី កិច្ចសន្យានេះត្រូវបានចុះហត្ថលេខា ។ រាល់ការចំណាយលើការអង្កេតនេះជាបន្ទុករបស់ភាគី "ខ" ។

## ប្រការ ២ : អំពីថេរវេលា

2.1 កិច្ចសន្យានេះមានរយៈពេលចំនួន 70 ឆ្នាំដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះតទៅ ។ នៅពេលផុតរយៈពេលនៃកិច្ចសន្យា ភាគី "ខ" ត្រូវប្រគល់ទីតាំង និងទ្រព្យសម្បត្តិទាំងអស់ដូចជា : ដើមឈើ, ដំណាំ, សំណង់អាគារ, រោងចក្រ និងសំភារៈបរិក្ខាផ្សេងៗ ។ ល ។ ជូនភាគី "ក" វិញ ។

2.2 រយៈពេល 01 ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី "ខ" អាចសុំជួលទីតាំងធ្វើវិនិយោគបន្តទៅទៀត ។ ការបន្តអាចធ្វើឡើងបានក្នុងករណីមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដោយយោលទៅតាមការអនុវត្តកន្លងមករបស់ភាគី "ខ" គោលនយោបាយរបស់រាជរដ្ឋាភិបាល នៅពេលនោះនឹងមានការពិភាក្សាដោយមានការឯកភាពពីភាគី "ក" ដែលជាលក្ខ័ណ្ឌសំរាប់កិច្ចសន្យាថ្មី ។

## ប្រការ ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និង កម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី "ខ" គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ចភ្ជាប់ជាឧបសម្ព័ន្ធ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

3.1 គោលដៅផលិតកម្ម-អាជីវកម្ម :

3.1.1 : ផលិតកម្មចំបង : កសិ-ឧស្សាហកម្ម មានអំពៅ និងដំឡូងមី

3.1.2 : ផលិតកម្មបន្ទាប់បន្សំ :ដំណាំផ្សេងៗ ទៀត

3.1.3 : សាងសង់រោងចក្រ : រោងចក្រកែច្នៃស្ករអំពៅ និងម្សៅដំឡូងមី និង រោងចក្រកែច្នៃកាកសំណល់កសិផល ។

3.1.4 : ភាគី "ខ" មានសិទ្ធិសុំកែប្រែមុខដំណាំដូចមានចែងក្នុងចំណុច 3.1.1 និង 3.1.2 ខាងលើ មកភាគី "ក "

3.2 កម្មវិធីប្រើប្រាស់ដីទីតាំង : ភាគី "ខ" ត្រូវប្រើផ្ទៃដីដែលបានរៀបរាប់ក្នុងប្រការ 1.1 នៃកិច្ចសន្យានេះក្នុងរយៈពេល 10 ឆ្នាំដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះតាមផែនការដូចខាងក្រោម :

ឆ្នាំទី 1 : 500 ហិកតា

ឆ្នាំទី 2 : 500 ហិកតា

ឆ្នាំទី 3 : 750 ហិកតា

ឆ្នាំទី 4 : 750 ហិកតា

hohong

| | | |
|---|---|---|
| ឆ្នាំទី 5 | 750 | ហិកតា |
| ឆ្នាំទី 6 | 750 | ហិកត |
| ឆ្នាំទី 7 | 1000 | ហិកតា |
| ឆ្នាំទី 8 | 1000 | ហិកតា |
| ឆ្នាំទី ៩ | 1000 | ហិកតា |
| ឆ្នាំទី 10 | 1000 | ហិកតា |

## ប្រការ ៤ : អំពីប្រាក់កក់ និង ថ្លៃឈ្នួល

4.1 ប្រាក់កក់ : ភាគី "ខ" ត្រូវបង់ប្រាក់កក់ចំនួន 5.000 $ ( ប្រាំពាន់ដុល្លាអាមេរិក ) សំរាប់ធានាការអនុវត្តន៍កិច្ចសន្យានេះ ។ ប្រាក់កក់នេះត្រូវបង់យ៉ាងយឺតបំផុតរយៈពេលបីថ្ងៃក្រោយពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យា ។ ប្រាក់កក់នេះត្រូវបង្វិលសងវិញនៅពេលដែលភាគី "ខ" អនុវត្តការដាំដុះបប់តាមគំរោងក្នុងប្រការ 3 ។

4.2 ភាគី "ខ" ត្រូវបង់ឈ្នួលដីសម្បទានដោយគិតជាដុល្លាអាមេរិក ក្នុងមួយហិកតាក្នុងមួយឆ្នាំ ដូចប្រការ 1.1 នៃកិច្ចសន្យា ។ ដីសម្បទានសរុបទាំងអស់ ដែលអនុញ្ញាតអោយក្រុមហ៊ុនធ្វើអាជីវកម្មដូចប្រការ 1.1 នៃកិច្ចសន្យា ។ អត្រាថ្លៃឈ្នួលដីសម្បទាន និងពេលចាប់ផ្តើមយកថ្លៃឈ្នួល ត្រូវកំណត់ដោយគោលការណ៍គិតថ្លៃឈ្នួលដីសម្បទាន ដែលនឹងត្រូវបានអនុមត់ដោយរាជរដ្ឋាភិបាល ។ ប្រាក់ឈ្នួលត្រូវបង់ជាប្រចាំឆ្នាំ នៅរៀងរាល់ខែមករា ហើយត្រូវបង់យ៉ាងយឺតអោយបានមុនថ្ងៃទី 31 ខែមករា នៃឆ្នាំនិមួយៗ ។

4.3 ភាគី "ខ" យល់ព្រមបង់ឈ្នួលដីសម្បទានទៅតាមអត្រាប្រែប្រួលដែលសំរេចដោយរាជរដ្ឋាភិបាល ។

4.4 ក្នុងករណីមានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលតាមការកំណត់ ដូចមានចែងក្នុងប្រការ 4.2 ភាគី "ខ" ត្រូវទទួលពិន័យចំនួន 2 % ក្នុងមួយខែ លើទឹកប្រាក់ឈ្នួលប្រចាំឆ្នាំនិមួយៗ តាមចំនួនខែដែលយឺតយ៉ាវ ។ ការខកខានមិនបានបង់ប្រាក់ឈ្នួលទាំងស្រុងក្នុងរយៈពេលមួយឆ្នាំឡើងទៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាភាគី "ក" មានសិទ្ធិរឹបអូសប្រាក់កក់ និងដីសម្បទាន ព្រមទាំងដំណាំទាំងអស់ទុកជាសម្បត្តិរដ្ឋ ព្រមទាំងបញ្ឈប់កិច្ចសន្យាដោយមិនចេញសោហ៊ុយទូទាត់រាល់ការចំណាយរបស់ភាគី " ខ " ដែលអនុវត្តកន្លងមក ។

4.5 ប្រាក់ថ្លៃឈ្នួលដី និងប្រាក់កក់ធានាការអនុវត្តន៍កិច្ចសន្យា ត្រូវបង់ចូលថវិការដ្ឋនៅរតនាគារជាតិ-គណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

4.6 ភាគី "ខ" ត្រូវបង់ការពន្ធកិច្ចផ្សេងៗទៀតជូនរដ្ឋតាមច្បាប់ជាធរមាន ។

## ប្រការ ៥ : ការផ្ទេរសិទ្ធិ ការជួលបន្ត ឬ ការលក់កិច្ចសន្យា

5.1 ភាគី "ខ" អាចផ្ទេរសិទ្ធិទៅអោយឧត្តរាធិការីរបស់ខ្លួនបាន ។ ដែលហៅថាឧត្តរាធិការីស្របច្បាប់ គឺជាបុគ្គលទាំងឡាយណាដែលភាគី "ខ" ប្រគល់អោយស្នងកេរមរតករបស់ខ្លួននៅចំពោះមុខច្បាប់ ។ ការប្រកាសជូនដំណឹងស្តីពីការផ្ទេរសិទ្ធិ ឬសំបុត្រណាមួយទៅអោយឧត្តមករីជន ត្រូវជូនដំណឹងទៅភាគី "ក " យ៉ាងតិច 03 ខែមុនពេលផ្តើមអនុវត្ត ។

5.2 ភាគី "ខ" ក្រោមសិទ្ធិទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់និងកិច្ចសន្យានេះ អាចសហការជាមួយក្រុមហ៊ុនដៃគូររបស់ខ្លួន ដើម្បីអភិវឌ្ឍន៍ផលិតកម្ម-អាជីវកម្មដែលស្ថិតនៅក្នុងក្របខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យានេះ ។

5.3 ក្នុងករណីនេះ ភាគី "ខ" ជួលបន្ត ឬលក់កិច្ចសន្យានេះ ភាគី "ខ" ត្រូវអនុវត្តតាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងមានការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមសំណើរបស់ភាគី "ក" ។

5.4 ដើម្បីរកទុនពីធនាគារក្នុង និងក្រៅប្រទេស មកពង្រីកការវិនិយោគទុនបន្ថែម ភាគី "ខ" មានសិទ្ធិយកដំណាំ និងទ្រព្យសម្បត្តិ ដែលបានចំណាយទុនវិនិយោគកន្លងមកនៅលើដីសម្បទាននោះ សំរាប់យកទៅជាធានាបំណុល ដោយមានការជួយគាំទ្រពីភាគី "ក" ។

## ប្រការ ៦ : សិទ្ធិ និង ភារកិច្ចរបស់ភាគី " ក "

ភាគី "ក" មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម :

6.1 ជួយរិះរកវិធានការចាំបាច់ទៅស្ថាប័នដែលពាក់ព័ន្ធដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយដែលមានអ្នកប្រព្រឹត្តបទល្មើសរំលោភលើសិទ្ធិរបស់ភាគី " ខ "ក្នុងក្របខ័ណ្ឌកិច្ចសន្យានេះក្នុងការអភិវឌ្ឍន៍និងការប្រើប្រាស់ទីតាំង ឬ រឹបអូសយកផ្នែកណាមួយនៃទីតាំង ។

6.2 តាមដានត្រួតពិនិត្យលើ :

- ការអនុវត្តន៍កិច្ចសន្យា
- ផលប៉ះពាល់លើបរិស្ថាន
- ការងារបច្ចេកទេស និង កម្មវិធីផលិតកម្ម-អាជីវកម្ម

## ប្រការ ៧ ៖ សិទ្ធិ និង ភារកិច្ចរបស់ភាគី " ខ "

ភាគី " ខ "មានសិទ្ធិ និង ភារកិច្ចដូចខាងក្រោម :

7.1 យល់ព្រមបង់ប្រាក់កក់ និង ថ្លៃឈ្នួលត្រឹមត្រូវតាមប្រការ 4 នៃកិច្ចសន្យានេះរហូតដល់ពេលចប់អាណត្តិកិច្ចសន្យា ។

7.2 ភាគី " ខ "យល់ព្រមទទួលបន្ទុកចំណាយលើការអង្កេតសិក្សាដូចមានចែងក្នុងប្រការ 1.4 ។

7.3 មានសិទ្ធិជ្រើសរើសពលកម្មក្នុងស្រុក ឬជួលអ្នកឯកទេសបរទេស ដើម្បីជួយណែនាំ ឬបង្ហាត់បង្ហាញអំពីការងារបច្ចេកទេស អាជីវកម្មផលិតកម្មតាមសេចក្តីត្រូវការចាំបាច់របស់ខ្លួន ក្នុងករណីគ្មានអ្នកឯកទេសនៅក្នុងប្រទេសដោយគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

7.4 យកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាពនិងការអប់រំដល់បុគ្គលិក កម្មករ និងគ្រួសាររបស់គេ ដោយខិតខំកសាងលំនៅដ្ឋាន មន្ទីរពេទ្យ វត្តអារាម សាលារៀន មណ្ឌលកំសាន្តលំហែកាយ ។ ល ។ ដោយផ្អែកតាមលទ្ធភាពរបស់ក្រុមហ៊ុន ។

7.5 អនុវត្តការងារអាជីវកម្មតាមគំរោងផែនការដូចជា : ការកាប់ឆ្ការព្រៃ, ការធ្វើផ្លូវ, ការដាំដុះ និងថែទាំ ។ ល ។ ដោយគោរពលក្ខខ័ណ្ឌនិរន្តភាពរបស់ទីតាំង និង ផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមកពីការធ្វើអាជីវកម្ម-ផលិតកម្ម ។

7.6 រៀបចំធ្វើផលិតកម្ម-អាជីវកម្ម តាមផែនការដូចមានចែងក្នុងរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ចរបស់ខ្លួន និងដូចក្នុងប្រការ 3 និងប្រការ 7 ចំណុច 7.3 នៃកិច្ចសន្យានេះនៅលើផ្ទៃដីដែលរដ្ឋប្រគល់ជូន ។

7.7 មានសិទ្ធិលក់ដូរ-ប្រមូលទិញ បែងចែកចរាចរផលិតផលគ្រប់ប្រភេទទាំងនៅក្នុង និងក្រៅប្រទេសតាមគោលការណ៍រដ្ឋជាធរមាន ។

7.8 ចំពោះការនាំចូលទព្វសំភារៈគ្រឿងចក្រ គ្រឿងបន្លាស់ វត្ថុធាតុគីមី ដែលបំរើអោយការធ្វើផលិតកម្ម-អាជីវកម្ម ពាក់ព័ន្ធនិងការបង់ពន្ធអាករផ្សេងៗគឺអាស្រ័យដោយច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាកំណត់ ។

7.9 ត្រូវអនុញ្ញាតអោយភាគី "ក" និងស្ថាប័នពាក់ព័ន្ធ តាមដាន ត្រួតពិនិត្យ ការយកចិត្តទុកដាក់ពីផលប៉ះពាល់លើបរិស្ថាន ។ ត្រូវអនុវត្តតាមការណែនាំរបស់ភាគី "ក" និងស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការពារបរិស្ថាន ។

## ប្រការ ៨ : ការអនុញ្ញាតអោយសាងសង់

8.1 តាមរយៈនេះ ភាគី "ខ" ត្រូវបានអនុញ្ញាតអោយអនុវត្តរាល់កិច្ចការសំណង់លើទីតាំងដែលស្រប តាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងសមស្របនិងទិសដៅការងារដូចក្នុងប្រការ 3 នៃកិច្ចសន្យា ។

8.2 រាល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា ទំនប់ ប្រឡាយ ដែលអាចអោយមានផល ប៉ះពាល់ដល់តំបន់ជុំវិញ ត្រូវមានការអនុញ្ញាតពីភាគី "ក" ឬ ស្ថាប័នពាក់ព័ន្ធ ។

## ប្រការ ៩ : សិទ្ធិនៃការគ្រប់គ្រង

រាល់អចលនទ្រព្យ និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសមិទ្ធិផលទាំងអស់ដែលបង្កើតឡើងដោយ ភាគី "ខ" ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី "ខ" រហូតផុតរយៈពេលនៃកិច្ចសន្យា ។

## ប្រការ ១០ : ការបញ្ចប់កិច្ចសន្យា

10.1 ភាគី "ខ" មានសិទ្ធិដកហូតចេញពីគំរោងការងារទាំងមូល ឬផ្នែកណាមួយ ក្នុងលក្ខខ័ណ្ឌមិន អាចគ្រប់គ្រងបាន និងត្រូវមានការឯកភាពពីភាគីទាំងសងខាង ។ រដ្ឋាភិបាលធានាទូវការវិល ត្រឡប់ប្រកបដោយសុវត្ថិភាពបុគ្គលិកបរទេសរបស់ក្រុមហ៊ុន និងក្រុមគ្រួសាររបស់គេ ហើយ ការយកត្រឡប់ទៅវិញ ឬការលក់សំភារៈបរិក្ខារោងចក្រនានា នាវាដាក់ម៉ាស៊ីន, នាវាផ្ទុកទំនិញ, យានយន្តផ្សេងៗទៀត និងប្រដាប់ប្រដារព្រមទាំងមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត គ្រឿងដាក់ភ្ជាប់ នៅមួយកន្លែងត្រូវធ្វើទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។

10.2 ក្នុងករណីដែលភាគី "ខ" ដកខ្លួនដោយខ្លួនឯងនោះ ភាគី "ខ" ត្រូវទទួលខុសត្រូវតាម មាត្រាទី 23 នៃច្បាប់វិនិយោគ ។

10.3 ប្រសិនបើភាគី "ខ" មិនអនុវត្តពេញលេញលក្ខខ័ណ្ឌណាមួយនៃកិច្ចសន្យានេះ ឬសេចក្ដីសំរេចនានា នៃច្បាប់របស់ព្រះរាជាណាក្រកម្ពុជា រាជរដ្ឋាភិបាលមានសិទ្ធិបញ្ឈប់កិច្ចសន្យានេះដោយគ្មានលក្ខខ័ណ្ឌ នឹងមិនសងការខាតបង់ ។ ការបញ្ឈប់បែបនេះនឹងនាំអោយមានការរឹបអូសទ្រព្យសម្បត្តិរបស់ភាគី "ខ" ជាសម្បត្តិរដ្ឋ ។

10.4 ក្នុងករណីដែលភាគី " ខ " មិនបានគោរពតាមកិច្ចសន្យានេះ ហើយមិនបានបំពេញសកម្មភាព ផលិតកម្មនៅក្នុងតំបន់សម្បទានក្នុងរយៈពេល 01 ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះ

រាជរដ្ឋាភិបាលមានសិទ្ធិបញ្ឈប់កិច្ចសន្យានេះដោយគ្មានលក្ខខ័ណ្ឌ និងគ្មានការសងនូវការខាតបង់ ។ ការបញ្ឈប់បែបនេះ និងនាំអោយមានការរឹបអូសប្រាក់កក់របស់ភាគី " ខ " ជាសម្បត្តិរដ្ឋ ។

## ប្រការ ១១ : វិវាទ និង ការដោះស្រាយ ( អាជ្ញាកណ្តាល )

11.1 ក្នុងករណីដែលមានវិវាទកើតក្នុងរយៈពេលនៃការអនុវត្តកិច្ចសន្យានេះ ភាគីទាំងពីរនឹងសំរបសំរួលដោះស្រាយដោយគោលគោរពសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីនីមួយៗ ដែលមានចែងក្នុងកិច្ចសន្យានេះ ។

11.2 ក្នុងករណីដែលភាគីទាំងពីរមិនអាចសំរបសំរួល ឬដោះស្រាយវិវាទនេះបានក្នុងរយៈពេល ៦០ ថ្ងៃ វិវាទនេះត្រូវដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជួយសំរួល និង ដោះស្រាយ ។

11.3 ក្នុងករណីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅតែមិនអាចដោះស្រាយវិវាទនេះបានក្នុងរយៈពេល 30 ថ្ងៃ ក្រោយពីបានទទួលសំណើដូចមានចែងក្នុងចំណុច 11.2 ភាគីទាំងពីរ ត្រូវបញ្ជូនសំណុំឯកសារនៃវិវាទនេះទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

## ប្រការ ១២ : ការទុកជាមិនបានការនូវភាគខ្លះ

ប្រសិនបើលក្ខខ័ណ្ឌណាមួយនៃកិច្ចសន្យានេះត្រូវទុកជាមិនបានការ ឬគ្មានប្រសិទ្ធិភាពផ្នែកដទៃទៀត ដែលនៅសល់ត្រូវមានសុពលភាព ដូចដែលមានសរសេរជាលាយលក្ខអក្សរចំពោះវិសាលភាព ទាំងអស់ដែលច្បាប់បានអនុញ្ញាត ។

## ប្រការ ១៣ : ច្បាប់អភិបាល

ការព្រមព្រៀងនៃកិច្ចសន្យានេះ ត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១៤ : ការព្រមព្រៀងទាំងស្រុង

ឯកសារនេះមានការព្រមព្រៀងទាំងស្រុងពីភាគីទាំងពីរ ហើយបដិសេធចោលនូវការព្រមព្រៀង ទាក់ទងការតំណាង និងការព្រមព្រៀងទាំងអស់ដែលមានពីមុន មិនថាដោយផ្ទាល់មាត់ ឬដោយសរសេរជាលាយល័ក្ខអក្សរដែលមានទាក់ទិននឹងកិច្ចសន្យានោះឡើយ កិច្ចសន្យានេះមិនអាចកែប្រែ ឬផ្លាស់ប្តូរបានទេ លើកលែងតែមានសរសេរជាលាយល័ក្ខអក្សរ ដែលមានចុះហត្ថលេខា និង ទទួលស្គាល់ដោយភាគីទាំងពីរ ។

hohour

## ប្រការ ១៥ : ករណីប្រធានសក្តិ

ក្នុងព្រឹត្តិការណ៍ដែលភាគីទាំងពីរមិនអាចបំពេញករណីកិច្ចរបស់ខ្លួនជាផ្នែកឬទាំងស្រុងបាន អនុលោមទៅតាមលក្ខខ័ណ្ឌផ្សេងៗនៃកិច្ចសន្យានេះដោយសារតែករណីប្រធានសក្តិ ភាគី "ខ" ត្រូវប្រកាសប្រាប់ភាគី "ក" ដោយសរសេរជាលាយលក្ខអក្សរបញ្ជាក់ពីហេតុផលរបស់ខ្លួន ហើយកាតព្វកិច្ចរបស់ភាគី "ខ" នឹងត្រូវបញ្ឈប់ជាបណ្តោះអាសន្ន ក្នុងកំឡុងពេលនៃរយៈពេលដែលជាប់ពាក់ព័ន្ធនោះ ។

ពាក្យ : ករណីជាប្រធានសក្តិ រួមមានភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាម រញ្ជួយ ផែនដី ។ ល ។ ការរំជើបរំជួលនៃផ្នែកស៊ីវិល សកម្មភាពការបះបោរ កុប្បកម្ម ការផ្ទុះ ផ្សេងៗ ការឆ្លងរាលដាលនៃជំងឺផ្សេងៗ ព្រមទាំងព្រឹត្តិការណ៍ ឬកាលៈទេសៈផ្សេងៗទៀត ដែលហួសពីការគ្រប់គ្រងសមស្របរបស់ភាគីទាំងពីរ ។

## ប្រការ ១៦ : សិទ្ធិលើធនធានធម្មជាតិ និង កេរដំណែល

16.1 មុនពេលបានដីសំរាប់អភិវឌ្ឍន៍ ភាគី "ខ " ត្រូវសុំការយល់ព្រមពីភាគី "ក " ក្នុងការកាប់រំលំកៃច្នៃ និងដឹកជញ្ជូនឈើដែលមាននៅលើដីនោះ នឹងត្រូវបង់ថ្លៃឈើជូនភាគី "ក" ដោយផ្អែកតាមគោលការណ៍ និងច្បាប់គ្រប់គ្រងព្រៃឈើជាធរមាន ។

16.2 នៅក្នុងការកាប់គាស់ដីសំរាប់ធ្វើផលិតកម្ម-អាជីវកម្ម ប្រសិនបើរកឃើញរ៉ែ ត្បូង មាស ឬ វត្ថុដែលជាកេរដំណែលផ្សេងៗ របស់ជាតិ នៅលើដី ឬក្រោមដី ត្រូវទុកជាទ្រព្យសម្បត្តិ របស់រដ្ឋ ។

## ប្រការ ១៧ : ភាសា

កិច្ចសន្យានេះធ្វើនៅរាជធានីភ្នំពេញ ជាភាសាខ្មែរ ចំនួន 15 ច្បាប់ ហើយច្បាប់ នីមួយៗ មានតំលៃស្មើគ្នា ។

## ប្រការ ១៨ : ការចាប់ផ្តើម និង បញ្ចប់

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ 2000 ហើយត្រូវផុតកំណត់នៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ 2070 ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ 2000

តំណាងភាគី " ខ "
នាយកក្រុមហ៊ុន ឈាង ហួហុង អាហារណ៍ និហារណ៍
និងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ

លី មាន

តំណាងភាគី " ក "
រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់
និង នេសាទ

ឈរា សុខ

<u>កន្លែងតំកល់ឯកសារ</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងបរិស្ថាន
- សាលាខេត្តបាត់ដំបង
- មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង
- ភាគី " ក "
- ភាគី " ខ "
- កាលប្បវត្តិ-ឯកសារ